ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

-----------

តុលាការកំពូល

-----------

សភាផ្នែកព្រហ្មទណ្ឌ

សំនុំរឿងព្រហ្មទណ្ឌ

លេខ : ៣៦

ចុះថ្ងៃទី២៥ខែសីហា ឆ្នាំ១៩៥៨

សាលដីកា

--------

លេខ : ៣០

ចុះថ្ងៃទី១៤ខែតុលា ឆ្នាំ១៩៥៨

តាងនាមប្រជារាស្ត្រខ្មែរ

តុលាការកំពូល

----------

ក្នុងបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៤ ខែសីហា ឆ្នាំ-១៩៥៨ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះ ដូចតទៅ :

| | | | | |
|---|---|---|---|---|
| ១ - | ឯកឧត្តម | ទិត | មន្ត្រី | ប្រធាន |
| ២ - | លោក | ឈឹម | ស៊ីផល | ចៅក្រម |
| ៣ - | លោក | សោម | សិរីវណ្ណ | ចៅក្រម |
| ៤ - | លោក | ប្រាក់ | ឌឹមសាន | ចៅក្រម |
| ៥ - | លោក | ជាស់ | សួនខឿន | ចៅក្រមរបាយការណ៍ |

ក្រឡាបញ្ជី លោក ប៉ុល វិណ្ណា

តំណាងមហាអយ្យការ

លោក សាយ សារី ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ ១៧៥ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ-១៩៥៨ របស់សាលាឧទ្ធរណ៍ និង សំនុំរឿងព្រហ្មទណ្ឌលេខ ៣៦ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៥៨ របស់-តុលាការកំពូល ។

ពីបទ : ចែករក្សា ជួញដូរ ប្រើប្រាស់ការំទុកខុសច្បាប់ ប្រព្រឹត្តក្នុងភ្នំពេញ -កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៥៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និង ផ្តន្ទាទោស តាមបញ្ញត្តិមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ - ៥ - ១៩៥៦ ។

- ជនជាប់ចោទឈ្មោះ ប្រាក់ បញ្ញា "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទស្រី អាយុ៣០ឆ្នាំ ជាតិខ្មែរ កើតនៅភូមិគរ ឃុំគរ ស្រុកសង្កែ ខេត្តបាត់ដំបង មុខរបរកាត់ដេរ និង ចែងការ ទីលំនៅសព្វថ្ងៃ ក្រុមទី៨ ផ្លូវលេខ២៧១ សង្កាត់ទឹកថ្លា ឃុំឫស្សីកែវ ក្រុងភ្នំពេញ ។ ឪពុកឈ្មោះស៊ុយ ខៀន "ស" ម្តាយឈ្មោះកែក អិន "រ" ប្តីឈ្មោះ គឹម សុន មានកូន២នាក់ ទោសពីមុនគ្មាន ។

- មេធាវី គ្មាន

- ជនរងគ្រោះ និង ជាដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះម៉ក់ ចាន់ថុល ភេទស្រី អាយុ-៥៩ឆ្នាំ ជាតិខ្មែរ មុខរបរ នៅផ្ទះ មានទីលំនៅសព្វថ្ងៃ ផ្ទះលេខ៣៦ ផ្លូវលេខ១៤០ ក្រុមទី៧៤ សង្កាត់

មននារមប្យ ឈ្មោះមករា ក្រុងភ្នំពេញ ។

- មេធាវី គ្មាន

- តាមបណ្តឹងសាទុក្ខលេខ ៣៣ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៨៨ របស់ជនជាប់ចោទ ឈ្មោះ ប្រាក់ បញ្ញា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៧៥ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៨៨ របស់សាលាឧទ្ធរណ៍ លើសាលដីកាខាងដើម ។

- តាមរបាយការណ៍លេខ៤៧ - ៨៨ ន.ប.ត ចុះថ្ងៃទី២០ - ៧ - ១៩៨៨ របស់ការិយាល័យព្រហ្មទណ្ឌកិច្ចស្រាលរាជធានីភ្នំពេញ បានទទួលពាក្យបណ្តឹង ពីជនរងគ្រោះឈ្មោះ ម៉ក់ ចាន់ថុល ចុះថ្ងៃទី១៩ - ៧ - ១៩៨៨ បានប្តឹងពីករណីចោរប្លន់ ម៉ូតូលេខ៥០ គុបក្រុងអាគុយប្លក កាលពីថ្ងៃទី១៩ - ៧ - ១៩៨៨ វេលាម៉ោង ១១និង២០នាទីនៅត្រង់ចំណុចបរិវេណសាលាគរុកោសល្យភូមិភាគរាជធានីភ្នំពេញ ។ បន្ទាប់មកនៅថ្ងៃទី១៩ - ៧ - ១៩៨៨ ដដែលនេះការិយាល័យព្រហ្មទណ្ឌកិច្ចស្រាលក៏បានទទួលរបាយការណ៍ បន្ថែមពីប្រជាជនល្អឈ្មោះ ជា សុថារ័ត្ន ភេទប្រុស អាយុ៣០ឆ្នាំ នៅផ្ទះសង់ថ្មី សង្កាត់ទឹកថ្លា ខណ្ឌ- ឫស្សីកែវ ក្រុងភ្នំពេញ បានរាយការណ៍ពីសកម្មភាពប្លន់ម៉ូតូខាងលើនេះ ហើយគេបានស្គាល់ច្បាស់ចំពោះ ជនល្មើសដែលធ្វើសកម្មភាពប្លន់ម៉ូតូ នៅក្នុងសាលាគរុកោសល្យភូមិភាគរាជធានីភ្នំពេញ កាលពីថ្ងៃទី១៩ - ៧ - ១៩៨៨ នេះ ។

- បានឃើញដីកាសំរេចលេខ ៣៦៨ន.ព្រ ចុះថ្ងៃទី០៣ - ៨ - ១៩៨៨ របស់ចៅក្រមស៊ើបអង្កេត នៃតុលាការក្រុងភ្នំពេញ ដែលបានសំរេច :

១ - ទទួលពិនិត្យធានា ឈ្មោះនារី ប្រាក់ បញ្ញា នៅក្រៅឃុំបណ្តោះអាសន្ន ចុះថ្ងៃទី០១ - ៨ - ១៩៨៨ របស់លោក គង់ ពេង ជាមេធាវី ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែ បដិសេធចោលដោយផ្ទុយនឹងគតិច្បាប់ ។

២ - មិនដោះលែងឈ្មោះនារី ប្រាក់ បញ្ញា អោយនៅក្រៅឃុំបណ្តោះអាសន្ន ទៀត ។

- បានឃើញបណ្តឹងឧទ្ធរណ៍លេខ ២៧គ ចុះថ្ងៃទី០៣ - ៨ - ១៩៨៨ របស់លោកគង់ ពេង ជា មេធាវី ដែលប្តឹងតវ៉ាពី ដីកាសំរេចលេខ៣៦៨ន.ព្រ ចុះថ្ងៃទី០៣ - ៨ - ១៩៨៨ ត្រង់ចំណុច ទី២ នៃ ដីកាសំរេចខាងដើម ។

- បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ អម សាលាឧទ្ធរណ៍ ថា : ចំពោះ អំពើប្រព្រឹត្តរបស់ នាងប្រាក់ បញ្ញា គឺបទ ថែរក្សាអាវុធ ជួញដូរ និង ប្រើប្រាស់អាវុធខុសច្បាប់ ដូចច្នេះការដែលអោយជនជាប់ចោទនេះនៅក្រៅឃុំ បណ្តោះអាសន្ននាំអោយមានការប៉ះពាល់ ដល់ នីតិវិធីស៊ើបអង្កេត ។ ដូច្នេះគួរក្រុមប្រឹក្សាជំនុំជំរះទុក នាងប្រាក់ បញ្ញា ក្នុងឃុំ ដើម្បីងាយស្រួល ដល់ការស៊ើបអង្កេត ។

- បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ១៧៥ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៨៨ របស់សាលា

សា/

ឧទ្ធរណ៍ ដែលបានសំរេច :

១ - ទទួលពាក្យបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី៣ - ៨ - ១៩៩៨ របស់ឈ្មោះ គង់ ហេង ជាមេធាវីរបស់ឈ្មោះ ព្រាក់ បញ្ញា ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោលដោយទាល់ខុស និងគតិច្បាប់ ។

២ - តម្កល់ដីកាសំរេចលេខ០៣៦/៩៨ត.ប្រព ចុះថ្ងៃទី៣ - ៨ - ១៩៩៨ របស់ចៅក្រមស៊ើបអង្កេត តុលាការក្រុងភ្នំពេញ ទុកជាបានការ ។

៣ - សាលដីកានេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ ។ បើកផ្លូវសារទុក្ខក្នុងកំណត់ច្បាប់ ។

- បានឃើញបណ្តឹងសារទុក្ខលេខ ៣៣ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៨ របស់អ្នកស្រី ព្រាក់ - បញ្ញា ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ១៧៥ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨ លើសាលដីកាទាំងមូល ។

- បានឃើញសារណា ចុះថ្ងៃទី៣ ខែកញ្ញា ឆ្នាំ១៩៩៨ របស់អ្នកស្រី ព្រាក់ បញ្ញា " ជា - ម្ចាស់បណ្តឹងសារទុក្ខ " ធ្វើឡើងក្នុងកំណត់ច្បាប់ ។

- បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការ អម តុលាការកំពូល ថា :

១ - បណ្តឹងសារទុក្ខរបស់ជនល្មើស ស្ថិតនៅក្នុងកំណត់ច្បាប់ គប្បីលើកយកមកពិនិត្យពិចារណា ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌ លេខ ១៧៥ ចុះថ្ងៃទី១៩ - ៨ - ៩៨ របស់ សាលាឧទ្ធរណ៍ ។

- បានស្តាប់ចម្លើយអះអាងរបស់ ជនជាប់ចោទឈ្មោះ ព្រាក់ បញ្ញា ថា : បានជាខ្ញុំមិនសុខចិត្ត នឹង សាលដីកានេះ គឺនាងខ្ញុំអត់បានប្រព្រឹត្តអំពើអ្វីទាំងអស់ ចំពោះរឿងអាវុធទាំងនេះគឺគ្រាន់តែជួយយករបស់គេដើម្បីយកទៅប្រគល់ដើម្បីយកកំរៃធ្វើការតែប៉ុណ្ណោះ ។ ហើយនាងខ្ញុំនៅមានកូនតូចនៅចាំផ្ទះម្តាយជរាទៀត ។

- បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែម គឺតំណាងមហាអយ្យការគ្មានអ្វីបន្ថែមទៀតទេ .

- ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការ

- ក្រោយពីបានស្តាប់ចម្លើយដោះសារ របស់ជនជាប់ចោទ

- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

តុលាការកំពូល

- យល់ឃើញថា បណ្តឹងសារទុក្ខលេខ៣៣ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៨ របស់អ្នកស្រី ព្រាក់ បញ្ញា ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូល អាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា

១៤ នៃច្បាប់ស្ដីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្ដី ។

- យល់ឃើញថា ការដែលតុលាការថ្នាក់ក្រោមចោទប្រកាន់ទៅលើអ្នកស្រី - ព្រាក់ បញ្ញា ពីបទថែរក្សា និង ជួញដូរអាវុធនោះ គឺជាបទល្មើសមួយដោយឡែក មិនគួរដាក់បញ្ចូលរួមទៅក្នុងសំណុំរឿងផ្សេងទៀត ដែលមានការចោទប្រកាន់ ពីបទល្មើសប្លន់ និង ប្រើប្រាស់អាវុធខុសច្បាប់នោះឡើយ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍ យល់ឃើញថាមិនអនុញ្ញាតអោយជនជាប់ចោទនៅក្រៅឃុំ ដោយយកហេតុថា ការស៊ើបអង្កេតនៅមិនទាន់បញ្ចប់គ្រប់គ្រាន់នៅឡើយនោះ ជាការភ័ន្ត-ច្រឡំ ពីព្រោះថា ពាក្យសុំធានានៅក្រៅឃុំជាបណ្ដោះអាសន្ននោះបានសំអាងថា ខ្លួនមានទីលំនៅច្បាស់លាស់ មានកូនខ្ចីនៅក្ដៅដោះ និង មានជម្ងឺ ម្ដាយចាស់ជរានៅជាមួយ ប្ដីរបស់គេក៏ធ្ន និងធានាថាមិនគេចវេះពីសមត្ថកិច្ច ឃើញថាអាចអនុញ្ញាតអោយនៅក្រៅឃុំជាបណ្ដោះអាសន្នបាន ហើយ - បទល្មើសនេះ ក៏ជាបទមជ្ឈិមទៀតផង ។

- យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ១៧៥ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្ដីទកនេះ មានការខុសឆ្គងទាំងទំរង់ ទាំងអង្គច្បាប់ ។

ហេតុដូច្នេះ

វិនិច្ឆ័យសេចក្ដីចំពោះមុខជនជាប់ចោទ

១ - ទទួលបណ្ដឹងសាទុក្ខលេខ ៣៣ ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ១៩៩៨ របស់អ្នកស្រី ព្រាក់ បញ្ញា ទុកជាត្រឹមត្រូវតាមទំរង់ និង អង្គច្បាប់ ។

២ - ទុកជាមោឃៈសាលដីកាព្រហ្មទណ្ឌលេខ ១៧៥ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ-១៩៩៨ របស់សាលាឧទ្ធរណ៍ទាំងមូល ដោយឥតបង្វិល ។

៣ - អនុញ្ញាតអោយជនជាប់ចោទឈ្មោះ ព្រាក់ បញ្ញា ភេទស្រី អាយុ៣០ឆ្នាំ ទីលំនៅផ្ទះលេខថ្មី ក្រុមទី៨ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ នៅក្រៅឃុំជាបណ្ដោះអាសន្ន បុគ្គលតម្រូវអោយ លោក ពិន មន្ត្រីរិទ្ធ ទទួលខុសត្រូវចំពោះវត្តមានរបស់ឈ្មោះ ព្រាក់ បញ្ញា ចំពោះមុខតុលាការ ។

៤ - បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ៣៧ ចុះថ្ងៃទី២៥ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ទៅតុលាការក្រុងភ្នំពេញ ដើម្បីចាត់ការតាមនីតិវិធី ។

៥ - សាលដីកានេះប្រកាសក្នុងសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែ - តុលា ឆ្នាំ ១៩៩៨ ។